Student/Registration Number | | | | | | | | | | | Centre Number | | | | | |

# 2017 PUBLIC EXAMINATION

# Khmer

## Continuers Level

**Wednesday 18 October: 2 pm Australian Eastern Daylight Time**

Reading Time: 10 minutes
Writing Time: 2 hours and 30 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

## Section 1: Listening and Responding (30 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 1.
2. Write all your answers to the questions in Section 1 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2017*

**Part A** (Questions 1 to 3)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in ENGLISH.

**Marks** | You may make notes in this space.

**Text 1**

1. (a) Provide evidence from the text that the caller is leaving a message for his wife. **1**

______________________________________________________

______________________________________________________

(b) (i) What request does the caller make? **1**

______________________________________________________

______________________________________________________

(ii) What is the main reason that the caller makes this request? **1**

______________________________________________________

______________________________________________________

Marks | You may make notes in this space.

**Text 2**

2. (a) How does Rattana use language to show respect for his teacher? Give examples from the text to support your answer. **3**

___________________________________________________________

___________________________________________________________

___________________________________________________________

___________________________________________________________

___________________________________________________________

___________________________________________________________

(b) What will Rattana do in Brisbane? **2**

___________________________________________________________

___________________________________________________________

___________________________________________________________

___________________________________________________________

Marks

You may make notes in this space.

**Text 3**

3. (a) What is the relationship between Sokhon and Chanty? Give examples from the text to support your answer. **2**

(b) Why is the wedding being held on 14 April? **2**

(c) Why does Sokhon say that Chanty is lucky? **3**

**Part B** (Questions 4 to 6)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in KHMER.

**Marks** | You may make notes in this space.

**Text 4**

4. What is likely to attract people to study at the University of Bayon? **3**

តើអ្វីខ្លះដែលប្រហែលជាអាចទាក់ទាញចិត្តសិស្សមកចូលរៀននៅមហាវិទ្យាល័យបាយ័ន្ត?

___

___

___

___

___

___

Marks

You may make notes in this space.

**Text 5**

5. (a) Why was the selection process difficult for Bunrath? Give evidence from the text to support your answer. **2**

តើហេតុដូចម្តេចបានជាវិធីជ្រើសរើសមានការតានតឹងសម្រាប់ប៊ុនរ៉ាត់? ចូរផ្តល់ភស្តុតាងពីអត្ថបទដើម្បីគាំទ្រចំឡើយរបស់អ្នក។

___

___

___

___

___

(b) Explain three reasons why Bunrath is very happy living in Australia. **3**

ចូរអ្នកពន្យល់ពីបុព្វហេតុបីយ៉ាង ថាតើហេតុអ្វីបានជាប៊ុនរ៉ាត់សប្បាយចិត្តយ៉ាងខ្លាំងពេលរស់នៅក្នុងប្រទេសអូស្ត្រាលី។

___

___

___

___

___

___

| | Marks | You may make notes in this space. |
|---|---|---|

**Text 6**

6. (a) Why is Ravuth studying dance? **2**

ហេតុអ្វីបានជាវ៉ារុទរៀនខាងរបាំ?

(b) What challenges does Ravuth face in order to be a good dancer? **3**

តើវ៉ារុទត្រូវប្រឈមនឹងឧបស័គ្គអ្វីខ្លះដើម្បីក្លាយជាអ្នករបាំដ៏ពូកែ?

(c) Why does Ravuth say that the students have a special relationship with their teachers? **2**

ហេតុអ្វីបានជាវ៉ារុទនិយាយថាសិស្សទាំងឡាយមានទំនាក់ទំនង
ពិសេសជាមួយគ្រូទាំងឡាយរបស់គេ?

**End of Section 1**

**KHMER (CONTINUERS) EXAMINATION 2017**

**Section 1: Listening and Responding**

**PART A**

***Text 1***

*(Ringing phone)*

*(female)*

សួស្តី។ ខ្ញុំមិនអាចទទួលទូរស័ព្ទឥឡូវណោះបានទេ ដូច្នេះសូមមេត្តាទុកពាក្យបណ្តាំក្រោយសំឡេងថ្ងូន ហើយខ្ញុំនឹងទាក់ទងទៅវិញក្នុងពេលបន្តិចទៀត។

*(Tone)*

*(male)*

ណៃ! ម៉ាក់វា ឯងអត់ទៅណាទេអ្វីនៅម៉ោងបី? ចាំទៅយក រ៉ាវី ពីសាលាជំនួសខ្ញុំផងណ៎ា ព្រោះខ្ញុំឃឹតទៅប្រជុំបន្តិចហើយ ដោយខ្ញុំត្រូវចាក់សាំងផង សប់កង់ឡានផង និងត្រូវយកសំបុត្រទៅដាក់ប៉ុស្តិ៍ទៀត។ ខ្ញុំគិតថានឹងមកដល់ផ្ទះនៅក្រោយម៉ោង៧។ ខ្ញុំសង្ឃឹមថាម៉ាក់វាឯងនឹងមិនយល់ទាស់ទេ។

Text 2

រ = Rattana    គ = Teacher

រ    ជំរាបសួរអ្នកគ្រូ។ ខ្ញុំរតនាបាទ។

គ    អូ! រតនាអ្ហី ឯងសុខសប្បាយទេ?

រ    បាទអ្នកគ្រូ ខ្ញុំសុខសប្បាយទេ។ ខ្ញុំទូរស័ព្ទមកនេះដើម្បីចង់ជំរាបអ្នកគ្រូថា ថ្ងៃសៅរ៍ក្រោយ ខ្ញុំមិនអាចទៅសាលាទេ។

គ    មានបញ្ហាអីដែរ?

រ    បាទ ខ្ញុំត្រូវទៅប្រឹស្សិនជាមួយក្រុមកីឡាបាល់ទាត់របស់ខ្ញុំដើម្បីចូលប្រកួតយកជើងឯកប្រចាំឆ្នាំនៅថ្ងៃទី២០ ខែកក្កដា។

គ    តើថ្ងៃនោះចំថ្ងៃអី?

រ    បាទ ចំថ្ងៃព្រហស្បតិ៍ អ្នកគ្រូ។

គ    ប៉ុន្តែ ឯងអាចមកវិញទាន់ថ្ងៃសៅរ៍បានតើ?

រ    បាទខ្ញុំអាច ប៉ុន្តែម៉ាក់ខ្ញុំគាត់មកជាមួយខ្ញុំដែរ ហើយគាត់ចង់នាំខ្ញុំទៅលេងសាច់ញាតិរបស់ខ្ញុំពីរបីថ្ងៃ ដូច្នេះខ្ញុំមិនអាចទៅសាលានៅថ្ងៃសៅរ៍បានទេ។

គ    អូ! មិនអីទេអញ្ចឹង។ ឯងអាចដោនឡូតមេរៀនទាំងប៉ុន្មានពីគេហទំព័រថ្នាក់របស់យើងបាន។ កុំភ្លេចអោយកិច្ចការនៅផ្ទះមកខ្ញុំពេលឯងត្រឡប់មកវិញ។ ចូរមានសំណាងល្អក្នុងការប្រកួតដ៏ធំនេះ។ ខ្ញុំសង្ឃឹមថាធាតុអាកាសប្រាកដជាល្អ។

រ    ខ្ញុំសូមអរគុណអ្នកគ្រូច្រើនណាស់។ ចាំជួបគ្នាថ្ងៃក្រោយអ្នកគ្រូ។ ជំរាបលា។

*Text 3*

ច៑ = Chanty       ស៑ = Sokhon

ច	សួស្ដីសុខុន! សុខសប្បាយទេ?

ស	អ៊ូចន្ទី! ខ្ញុំសុខសប្បាយទេ។ ចុះឯងវិញ?

ច	ខ្ញុំគិតគូពិធីរៀបការរបស់ខ្ញុំជិតរួចហើយ។

ស	មួយឆ្នាំបានកន្លងទៅហើយតាំងពីឯងធ្វើពិធីភ្ជាប់ពាក្យមែនទេ? ខ្ញុំមានកិត្តិយសខ្លាំងណាស់ដែលបានទៅចូលរួមក្នុងពិធីភ្ជាប់ពាក្យឯងជាមួយនឹងសាច់ញាតិរបស់ឯងទាំងអស់កាលណោះ។ ហើយពេលណាឯងនឹងរៀបការ?

ច	ថ្ងៃអាទិត្យទី១៨មេសាឆ្នាំនេះ។

ស	ល្អណាស់ ចំថ្ងៃចូលឆ្នាំខ្មែរតែម្ដង មែនទេ?

ច	មែនហើយ។ ប៉ុន្តែគំនិតចំបងរបស់យើងគឺថ្ងៃសម្រាកយូរបុណ្យអ៊ីស្ទ័រ ដូច្នេះភ្ញៀវដែលមកពីឆ្ងាយមិនចាំបាច់ប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ។ វាគ្រាន់តែជាចៃដន្យដែលថ្ងៃអាពាហ៍ពិពាហ៍នេះចំថ្ងៃបុណ្យចូលឆ្នាំខ្មែរ។

ស	ឯងគិតគូបញ្ជីភ្ញៀវរួចហើយឬនៅហ្នឹង?

ច	នៅទេ ព្រោះខ្ញុំរង់ចាំចំនួនភ្ញៀវខាងគូដណ្ដឹងខ្ញុំ។ ប៉ុន្តែយើងបានសម្រេចថាប្រហែលជា៩០តុខាងខ្ញុំ។

ស	វ៉ាវ! ភ្ញៀវច្រើនណាស់ណ៎! ឯងប្រាកដជារវល់ខ្លាំងណាស់ ជាពិសេសក្នុងការអញ្ជើញភ្ញៀវ។

ច	មិនមែនទេ ម៉ាក់ប៉ាខ្ញុំជាអ្នករ៉ាប់រងហៅភ្ញៀវទាំងអស់។ គាត់ចាត់ចែងរកអ្នកធ្វើម្ហូបជួលភ្លេងបុរាណខ្មែរ និងជួលសំលៀកបំពាក់បុរាណខ្មែរផង។ គាត់ថែមទាំងជ្រើសរើសហូលសម្រាប់ពិធីជប់លៀងផង។ ឪពុកខ្ញុំស្គាល់គេច្រើនណាស់ពីព្រោះគាត់ធ្លាប់ធ្វើជាភ្នាក់ងារបម្រើសហគមន៍។ គូដណ្ដឹងខ្ញុំ ទោះបីជាគាត់មិនមែនជាសាសន៍ខ្មែរក៏ដោយ ក៏គាត់ចង់ធ្វើអ្វីៗតាមទំនៀមទំលាប់ខ្មែរទាំងអស់។ កិច្ចការដែលខ្ញុំត្រូវធ្វើគឺជ្រើសរើសឈុតសំលៀកបំពាក់អាពាហ៍ពិពាហ៍របស់ខ្ញុំ និងអញ្ជើញមិត្តភក្តិខ្ញុំដូចជាឯងជាដើម។

ស	ឯងសំណាងណាស់ដែលមានឪពុកម្ដាយល្អបែបនេះ។

**PART B**

***Text 4***

សេចក្ដីជូនដំណឹងពីសាកលវិទ្យាល័យបាយ័ន្ត។ សាកលវិទ្យាល័យយើងនឹងចាប់បើកអោយចុះឈ្មោះសម្រាប់ឆ្នាំក្រោយចូលរៀនវិជ្ជាជីវៈយ៉ាងច្រើនរួមមាន គណនេយ្យ ពត៌មានវិទ្យា គ្រប់គ្រង ច្បាប់ និងពាណិជ្ជកម្ម។ យើងបើកបង្រៀនសម្រាប់យកបរិញ្ញាប័ត្រ អនុបណ្ឌិត និង បណ្ឌិតដែលគេទទួលស្គាល់ក្នុងពិភពលោក។ យើងថែមទាំងផ្ដល់រៀងរាល់ឆ្នាំនូវអាហារូបករណ៍មួយចំនួនសម្រាប់ទៅសិក្សានៅបរទេសដូចជាប្រទេសអូស្ត្រាលី ចក្រភពអង់គ្លេស និង សហរដ្ឋអាមេរិក។ ពត៌មានបន្ថែមសូមអាននៅក្នុងវ៉ិបសាយរបស់យើង។

*Text 5*

ន = Neary  ប = Bunrath

ន  ហេឡូ។

ប  ហេឡូ។ សុខសប្បាយទេ?

ន  ចាំស សុខសប្បាយ។ ខ្ញុំឈ្មោះនារី។ ខ្ញុំហាក់ដូចជាមិនដែលឃើញប្អូនទេ មែនទេ?

ប  បាទ ខ្ញុំឈ្មោះប៊ុនរ៉ាត់ជានិស្សិតអាហារូបករណ៍មករៀនយកបរិញ្ញាប័ត្រចំនួនបីឆ្នាំ។

ន  អូ៎! ឯងមានសំណាងល្អណាស់ដែលត្រូវបានគេជ្រើសរើស។ តើឯងត្រូវធ្វើយ៉ាងម៉េចខ្លះដើម្បីបានមក?

ប  ខ្ញុំត្រូវប្រឡងសរសេរខាង IT ក្នុងចំណោមបេក្ខជនរាប់ពាន់នាក់ ហើយថែមទាំងត្រូវប្រឡងអោយបានជាប់ខាងសួរផ្ទាល់មាត់ផ្នែកភាសាអង់គ្លេសផង។ ខ្ញុំហាត់រៀននិយាយភាសាអង់គ្លេសរាល់ថ្ងៃចំនួន២ឆ្នាំមកហើយ។

ន  វ៉ូវ! ដូចជាពិបាកណាស់។ ឯងប្រាកដជាមនុស្សឆ្លាតខ្លាំងមែនទែន។ តើឯងត្រូវចំណាយប្រាក់កាសអស់ប៉ុន្មានទៅដើម្បីបានមក?

ប  មិនអស់អីទេ ព្រោះរដ្ឋាភិបាលអូស្ត្រាលីចេញថ្លៃសាលា ថ្លៃយន្តហោះ និងកន្លែងស្នាក់នៅ ហើយខ្ញុំអាចរកការងារធ្វើនៅប្រទេសអូស្ត្រាលីផង។

ន  ឯងចំជាមានសំណាងមែន! តើឯងមានអារម្មណ៍ឯកកោទេនៅទីនេះ? ហើយដែលមានបញ្ហានឹកផ្ទះទេ?

ប  នេះជាអ្វីដែលខ្ញុំព្រួយបារម្ភមុនពេលខ្ញុំមក។ ប៉ុន្តែឥឡូវណេះ ខ្ញុំមានមិត្តច្រើនណាស់តាំងពីខ្ញុំមកដល់។ គេទាំងឡាយជាមនុស្សរាក់ទាក់ណាស់ ហើយគេស្វាគមន៍ខ្ញុំល្អណាស់។ គេតែងនាំខ្ញុំទៅលេងកន្លែងផ្សេងៗ និងទៅចូលរួមក្នុងពិធីជប់លៀងដូចនេះជាច្រើន។ សំខាន់ជាងនេះទៅទៀតនោះ គេជួយរកការងារអោយខ្ញុំធ្វើផង។ ខ្ញុំសប្បាយចិត្តរស់នៅទីនេះណាស់ ប៉ុន្តែខ្ញុំនៅតែនឹកផ្ទះម្តងម្កាលដែរ។

ន  ល្អណាស់អញ្ចឹង!

*Text 6*

អ្នកសំភាស	បន្តពីរឿងភាគរបស់យើងដែលមានចំណងជើងថា 'ជីវិតប្រចាំថ្ងៃរបស់សិស្សម្នាក់' យើងបានជួប រ៉ាវុទជាអ្នករបាំក្មេងម្នាក់មកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ រ៉ាវុទ ហេតុអ្វីបានជាក្មួយមករៀនខាងរបាំ?

រ៉ាវុទ	ខ្ញុំរៀនរបាំពីព្រោះឪពុកនិងជីតាខ្ញុំធ្លាប់ជាអ្នករបាំប្រពៃណី។ គាត់បានលើកទឹកចិត្តខ្ញុំអោយរៀនរាំតាំងពីខ្ញុំមានអាយុត្រឹម៨ឆ្នាំម្ល៉េះ។ ខណៈដែលខ្ញុំបានដើរតាមគន្លងរបស់គ្រួសារខ្ញុំក្នុងការហាត់ហ្វឹកហ្វឺនជាអ្នករបាំប្រពៃណី ខ្ញុំក៏បានចាប់ផ្តើមហាត់រៀនខាងផ្នែករបាំប្រជាប្រិយ និងផ្នែកសំដែងល្ខោនខោលដែរ។

អ្នកសំភាស	តើក្មួយធ្វើអ្វីខ្លះក្នុងមួយថ្ងៃៗ?

រ៉ាវុទ	រាល់ព្រឹករៀងរាល់ថ្ងៃ ខ្ញុំហាត់រាំរបាំចំនួន៤ម៉ោង រួចខ្ញុំទៅផ្ទះ ញ៉ាំបាយ គេងមួយស្របក់ ហើយត្រឡប់មកសាលាវិញនៅពេលថ្ងៃដើម្បីរៀនមុខវិជ្ជាធម្មតាទាំងអស់ផ្សេងទៀត។ ខ្ញុំត្រូវតែឆ្លៀតហាត់ពត់ម្រាមដៃនិងម្រាមជើងរាល់ព្រឹកព្រលឹមនិងមុនចូលគេង។

អ្នកសំភាស	ចំជាហាត់មែន! តើក្មួយមកសាលារៀនដោយរបៀបណា?

រ៉ាវុទ	ខ្ញុំជិះកង់មកសាលារាល់ថ្ងៃ។ ខ្ញុំត្រូវចំណាយពេលអស់ជិតកន្លះម៉ោងទើបដល់សាលា។ ខ្ញុំសប្បាយនឹងជិះកង់ ហើយវាជួយអោយខ្ញុំមានកំលាំងមាំមួនផង។

អ្នកសំភាស	តើក្មួយយល់យ៉ាងម៉េចដែរចំពោះលោកគ្រូរបាំរបស់ក្មួយ?

រ៉ាវុទ	គាត់ទាំងអស់ល្អៗណាស់។ យើងមានទំនាក់ទំនងពិសេសណាស់ជាមួយគាត់។ យើងតែងយកទៀនធូបនិងផ្កាសម្រាប់ធ្វើពិធីបួងសួងរាល់ពេលមុនយើងហាត់របាំម្តងៗ។ គ្រូរបាំយើងតែងអោយពរដល់យើងអោយបានក្លាយជាអ្នករបាំដ៏ចំណានគ្រប់ៗគ្នា និងលើកទឹកចិត្តយើងអោយបញ្ជូនបន្តសិល្បៈបុរាណនេះដល់ក្មេងជំនាន់ក្រោយទៀត។

អ្នកសំភាស	យើងសូមជូនពរអោយក្មួយបានទទួលជោគជ័យក្នុងអាជីពជាអ្នករបាំ។ អរគុណក្មួយដែលបាននិយាយជាមួយយើង។

| Student/Registration Number | | | | | | | | | | | | Centre Number | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|

## 2017 PUBLIC EXAMINATION

# Khmer

## Continuers Level

## Section 2: Reading and Responding (25 marks)

**Instructions to Students**

1. Allow approximately 1 hour and 10 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2017*

**Part A** (Questions 7 and 8)
(10 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts (for example, by comparing, contrasting, summarising, and/or evaluating) and convey the information appropriately.*

---

7. Read the text and then answer in ENGLISH the questions that follow.

## ‘ទឹកចិត្តម្តាយ’ – រឿងមួយសម្រាប់យើងទាំងអស់គ្នា

‘ទឹកចិត្តម្តាយ’ ជាខ្សែភាពយន្តថ្មីខ្នាតធំមួយដែលបានចាប់បញ្ចាំងកាលពីថ្ងៃសុក្រមុននៅទីក្រុងភ្នំពេញ។ រឿងនេះរៀបរាប់អំពីសេចក្តីស្រឡាញ់របស់មាតាពីររូបចំពោះបុត្រាបុត្រីរបស់គេ។ មាតាម្នាក់ជាមាតាក្រីក្រ និងមាតាម្នាក់ទៀតជាមាតាអ្នកមានស្តុកស្តម្ភ។ មាតាអ្នកក្រត្រូវតែលះបង់ច្រើនជាង និងប្រើទ្រព្យសម្បត្តិបន្តិចបន្តួចដែលខ្លួនមានដើម្បីចិញ្ចឹមកូនរបស់គាត់។ មាតាទាំងពីរនាក់នេះបានឆ្លងកាត់ភាពជោគជ័យនិងភាពបរាជ័យក្នុងជីវិតដូចគ្នា ប៉ុន្តែគេដោះស្រាយបញ្ហាទាំងនោះខុសគ្នា។ នៅទីបញ្ចប់ កូនរបស់មាតាអ្នកក្របានទទួលជោគជ័យយ៉ាងខ្លាំងក្រោយពេលដែលមាតារបស់គេទើបបានទទួលមរណភាពរួច។ ផ្ទុយទៅវិញ កូនរបស់មាតាអ្នកមានក្លាយខ្លួនទៅជាអ្នកដើរក្នុងផ្លូវខុសច្បាប់។ ប៉ុន្តែអ្វីដែលធ្វើអោយទស្សនិកជនស្ទើរតែទាំងអស់ស្រក់ទឹកភ្នែកខ្លាំងនោះគឺមាតាអ្នកមាននេះនៅតែស្រឡាញ់កូនរបស់គាត់ដដែល ព្រោះគាត់ខិតខំប្រើគ្រប់មធ្យោបាយដែលគាត់អាចធ្វើទៅបានដើម្បីជួយស្រោចស្រង់និងគាំទ្រកូនរបស់គាត់។

ទស្សនិកជនភាគច្រើនយល់ស្របថាភាពយន្តនេះល្អណាស់ព្រោះវាឆ្លុះបញ្ចាំងពីជីវភាពពិតៗរបស់មាតាខ្មែរគ្រប់រូបក្នុងសម័យនេះ ហើយរឿងនេះនឹងផ្ញើសារយ៉ាងខ្លាំងដល់បុត្រាបុត្រីគ្រប់រូបអោយចេះតបស្នងសងគុណដល់មាតាបិតារបស់ខ្លួនក្នុងខណៈដែលខ្លួនអាចធ្វើបាន។

ខ្សែភាពយន្តនេះកំពុងចាក់បញ្ចាំងក្នុងប្រាំរោងកុនចំនួនមួយអាទិត្យហើយ ប៉ុន្តែនៅតែមានទស្សនិកជនចូលទស្សនាពេញៗរោង។

លំដាប់ថ្នាក់: ☆☆☆☆☆

អ្នកនិពន្ធ: វិចិត្រា

QUESTIONS

**Marks**

(a) What type of text is Text 7? Identify four features of the text to justify your answer. **3**

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

(b) Explain the meaning of the title of the text. **2**

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

8. Read the text and then answer in ENGLISH the question that follows.

ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧

មកដល់សារឿន

ឯងសុខសប្បាយទេ? ខ្ញុំស្ទើរតែមិនជឿថាឯងបានឮដំណឹងអំពីកុនរឿង ‘ទឹកចិត្តម្តាយ’ ទាល់តែសោះ។ ខ្ញុំបានទៅមើលរឿងនេះកាលពីអាទិត្យមុន។

ខ្ញុំយល់ថានេះជារឿងកុនដែលមានគុណភាពល្អបំផុតមួយដោយសារតែវាជាភាពយន្តខ្នាតធំ មានរូបច្បាស់ល្អ និងមានបច្ចេកទេសខាងសំឡេងក៏ល្អដែរ។ អ្នករើសតួធ្វើការបានល្អក្នុងការជ្រើសរើសតួសំដែង។ ទោះជាយ៉ាងណាក្តី វាជារឿងដ៏កំសត់មួយហើយខ្ញុំមិនចូលចិត្តរឿងកំសត់ទាល់តែសោះ។

ខ្ញុំយល់ថារឿងនេះមិនឆ្លុះបញ្ចាំងពីជីវភាពពិតរបស់គ្រួសារខ្មែរភាគច្រើនទេក្នុងន័យថាមានចំនួនគ្រួសារអ្នកក្រតិចណាស់ដែលអាចចញ្ចឹមកូនអោយបានទទួលជោគជ័យក្នុងជីវិត។ ផ្ទុយទៅវិញ គ្រួសារអ្នកមានភាគច្រើនមានអ្វីៗទាំងអស់ ប្រាក់កាស និងការគាំទ្រ។ល។ កូនរបស់គេភាគច្រើន ច្រើនតែបានទទួលការសិក្សាខ្ពស់ ដូច្នេះកូនទាំងនោះច្រើនបានទទួលមុខងារល្អ។

អុំ! មានបញ្ហាមួយទៀតដែលជួនកាលអ្នកសំដែងហាក់ដូចជាអានអត្ថបទពេលនិយាយ។ វាហាក់ដូចជាមិនធម្មតាទាល់តែសោះ។

ពេលណារឿងនេះត្រូវបានគេចាក់បញ្ចាំងនៅអូស្ត្រាលី ឯងត្រូវតែប្រាប់ខ្ញុំថាតើឯងយល់យ៉ាងណាដែរ។

លាហើយ
នីតា

QUESTION

**Marks**

Compare the views of the authors of Text 7 and Text 8. **5**



PLEASE TURN OVER

**Part B** (Question 9)
(15 marks)

---

*Your response will be assessed on how well you:*
- *demonstrate understanding of the stimulus text*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

9. Read the text and then answer the question in approximately 150 words in KHMER.

## សេចក្ដីជូនដំណឹង

ពុទ្ធិកសមាគមខ្មែរមានសេចក្ដីរីករាយនឹងសូមជូនដំណឹងដល់អស់លោកលោកស្រីទាំងអស់អោយបានជ្រាបថា៖ដើម្បីចូលរួមចំណែកក្នុងពិធីសម្ពោធសាលរបស់ខ្មែរទីមួយនៅប្រទេសអូស្ត្រាលី និងចូលរួមក្នុងពិធីបុណ្យចូលឆ្នាំសកលផងនោះ សមាគមយើងនឹងរៀបចំរាត្រីសមោសរមួយដែលនឹងប្រព្រឹត្តទៅតាមពេលវេលានិងទីកន្លែងដូចមានចែងខាងក្រោមនេះ។

| | |
|---|---|
| ពេលវេលា | ថ្ងៃអាទិត្យ ទី31 ខែធ្នូ ឆ្នាំ2017 |
| ទីកន្លែង | Khemera Hall |
| អាស័យដ្ឋាន | 45 James Avenue |

## កម្មវិធី

| | |
|---|---|
| 8.00 pm | សុន្ទរកថារបស់លោកប្រធានពុទ្ធិកសមាគមខ្មែរ |
| 8.05 pm | របាំជូនពរ សំដែងដោយក្រុមល្ខោនខ្មែរ |
| 8.15 pm | របាំប្រជាប្រិយសំដែងដោយក្រុមយុវជនខ្មែរ |
| 8.35 pm | នាទីកំប្លែងសំដែងដោយក្រុមយុវជនខ្មែរ |
| 8.45 pm | ល្ខោននិយាយរឿង 'កំហុសអ្នកណា?' សំដែងដោយក្រុមល្ខោនខ្មែរ |
| 9.15 pm | ការរាំលេងកំសាន្តជាមួយក្រុមតន្ត្រីអប្សរា |
| 11.50 pm | ការចាប់ឆ្នោតយករង្វាន់ |
| 12.00 pm | ការបាញ់កាំជ្រួច |

ចំណាំ: ម្ហូបអាហារនិងភេសជ្ជៈមានលក់ជូន។
មិនមានលក់សំបុត្រចូលទេ ប៉ុន្តែសូមអរគុណចំពោះវិភាគទាន

យើងខ្ញុំសង្ឃឹមថាអស់លោកលោកស្រីទាំងអស់ប្រាកដជានឹងអញ្ជើញមកចូលរួមក្នុងពិធីអបអរសាទរនេះជាមិនខានឡើយ។

QUESTION

You and your family have been living in Australia for 20 years. Your cousin in Cambodia, whom you have not met before, is planning to visit your family in November this year.

Write an email persuading your cousin to come in December so that your cousin can join your family at the Universal New Year celebrations and the celebrations of the first Khmer hall in Australia.

អ្នកនិងគ្រួសារអ្នកបានមករស់នៅប្រទេសអូស្ត្រាលីចំនួន២០ឆ្នាំហើយ។ បងប្អូនជីដូនមួយរបស់អ្នក នៅប្រទេសកម្ពុជា ដែលអ្នកមិនធ្លាប់បានជួបពីមុន មានគំរោងមកលេងគ្រួសារអ្នកក្នុងខែវិច្ឆិកាឆ្នាំនេះ។

ចូរអ្នកសរសេរអ៊ីមែលមួយផ្ញើទៅបងប្អូនជីដូនមួយរបស់អ្នក ដើម្បីបញ្ចុះបញ្ចូលគេអោយមកលេង ក្នុងខែធ្នូវិញ ដើម្បីអោយគេបានមកចូលរួមជាមួយគ្រួសារអ្នកក្នុងពិធីបុណ្យចូលឆ្នាំសកល និងក្នុង ពិធីសម្ពោធសាលខ្មែរទីមួយនៅប្រទេសអូស្ត្រាលី។

---

You may make notes in this space.

This page is intentionally blank

Question 9



PLEASE TURN OVER

**End of Section 2**

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

## 2017 PUBLIC EXAMINATION

# Khmer

## Continuers Level

### Section 3: Writing in Khmer (20 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2017

**Section 3** (Questions 10 to 12)
(20 marks)

---

*Your response will be assessed on how well you:*

- *demonstrate depth of treatment of information, ideas and/or opinions*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

Answer ONE question from this section in approximately 250 words in KHMER.

10. A multicultural organisation in Australia is interested in modern-day lifestyles of Cambodians living in Australia. Write an article for the organisation's website discussing the relevance of the Khmer proverb 'នំមិនធំជាងនាលិ' for Khmer communities in Australia.

    អង្គការពហុវប្បធម៌នៅប្រទេសអូស្ត្រាលីមានចំណាប់អារម្មណ៍ទៅនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនខ្មែរក្នុងសម័យថ្មីនៅប្រទេសអូស្ត្រាលី។ ចូរអ្នកសរសេរអត្ថបទសម្រាប់ចុះផ្សាយក្នុងវិបសាយរបស់អង្គការនេះ ដោយធ្វើការពិភាក្សាពីភាពសមស្របនៃសុភាសិតខ្មែរ 'នំមិនធំជាងនាលិ' សម្រាប់សហគមន៍ខ្មែរនៅប្រទេសអូស្ត្រាលី។

11. 'I won't do that again.'

    Write an imaginary story ending with the statement above. The story is for a competition being run by your Khmer community newspaper.

    'ខ្ញុំនឹងមិនធ្វើយ៉ាងនេះទៀតទេ។'

    ចូរអ្នកសរសេររឿងប្រឌិតមួយដោយបញ្ចប់នឹងឃ្លាខាងលើ។ រឿងនេះសរសេរសម្រាប់ដាក់ចូលការប្រកួតប្រជែងមួយ ដែលចាត់ចែងឡើងដោយសារពត៌មានសហគមន៍ខ្មែររបស់អ្នក។

12. You are visiting Cambodia for the first time. Write a letter to your Cambodian friend in Australia, expressing your feelings about seeing Cambodia, and commenting on the similarities and differences in the lifestyles of the two countries.

    អ្នកកំពុងតែបានទៅលេងប្រទេសកម្ពុជាជាលើកដំបូង។ ចូរអ្នកសរសេរសំបុត្រមួយច្បាប់ផ្ញើទៅមិត្តខ្មែររបស់អ្នកម្នាក់រស់នៅប្រទេសអូស្ត្រាលី ដោយរៀបរាប់អំពីអារម្មណ៍របស់អ្នកចំពោះការទស្សនាប្រទេសកម្ពុជា និងបញ្ចេញមតិអំពីភាពដូចគ្នានិងខុសគ្នានៃជីវភាពរស់នៅក្នុងប្រទេសទាំងពីរ។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page.

This page is intentionally blank

Question Number:



PLEASE TURN OVER

**End of Section 3**